ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Bureau des co-juges d'instruction**
**Office of the Co-Investigating Judges**
**សំណុំរឿងព្រហ្មទណ្ឌ**
**Dossier pénal/Criminal Case File**
**លេខ/No: 002/14-08-2006**

# ដីកាសម្រេចបដិសេធសំណើសុំដោះលែងឲ្យមានសេរីភាព

## Ordonnance de refus de mise en libert‟

## Order refusing the request for release

(អត្ថបទសម្រាប់ផ្សាយជាសាធារណៈ)

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក.")

បានឃើញវិធាន ៦៤.២ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **ខៀវ សំផន** ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការបំពានបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ** **ចុះថ្ងៃទី១២**

**ខែសីហា ឆ្នាំ១៩៥៩** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ ៦ ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក

បានឃើញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ ខៀវ សំផន សំរាប់រយៈពេលអតិបរមា ១ ឆ្នាំ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ (C26)

បានឃើញបណ្តឹងរបស់មេធាវីដើម្បីសុំឲ្យចេញដីកាដោះលែងឈ្មោះ ខៀវ សំផន ឲ្យនៅក្រៅឃុំ ដោយហេតុផលសុខភាព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ (C36)

បានឃើញដីកាជំទាស់ដល់ការដោះលែងឲ្យនៅក្រៅឃុំ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ (C36/III)

បានឃើញពាក្យបណ្តឹងសុំដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ២០០៨ (C40)

បានឃើញដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ២០០៨ (C40/I)

បានឃើញការជូនដំណឹងរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០០៨ (D40/III)

## ហេតុផលនៃសេចក្តីសំរេចៈ

### I- ភាពទទួលយកបាននៃបណ្តឹង ស្របតាមវិធាន ៦៤(៣)

១. សហព្រះរាជអាជ្ញាបានលើកឡើងថា ពាក្យសុំដោះលែងឲ្យនៅក្រៅឃុំធ្វើឡើងដោយ ខៀវ សំផន ត្រូវបដិសេធថាមិនអាចទទួលយកបានទេៈ ពាក្យសុំដោះលែងឱ្យនៅក្រៅឃុំលើកមុន ធ្វើឡើងដោយសហមេធាវី ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៨ គឺជាឧបសគ្គដល់ការដាក់ពាក្យបណ្តឹងថ្មី ដោយសារពុំមានការប្រែប្រួលនៃកាលៈទេសៈ ដូចដែលមានចែងនៅក្នុងវិធាន ៦៤(៣) នៃវិធានផ្ទៃក្នុង។

២. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វិធាន ៦៤(៣) ត្រូវបកស្រាយដោយតឹងរឹង ចំពោះចំនុចដែលទាក់ទងនឹងការផ្លាស់ប្តូរកាលៈទេសៈ តាមធម្មជាតិ ការកន្លងផុតទៅនៃពេលវេលា ក៏អាចជាកត្តាមួយ ដែលបណ្តាលឲ្យមានការប្រែប្រួលនៃកាលៈទេសៈបានដែរ។

៣. ជាក់ស្តែង ពាក្យបណ្តឹងសុំដោះលែងឲ្យនៅក្រៅឃុំថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៨ គឺឈរលើមូលដ្ឋាននៃស្ថានភាពសុខភាពរបស់ជនត្រូវចោទ។ ចាប់តាំងពីពេលមានពាក្យបណ្តឹងនោះមក ការធ្វើកោសល្យវិច័យផ្នែកវេជ្ជសាស្ត្រពីរលើក ត្រូវបានធ្វើឡើងតាមការស្នើសុំរបស់សហចៅក្រមស៊ើបអង្កេត ហើយបាននាំមកនូវការបញ្ជាក់ដ៏សំខាន់អំពីស្ថានភាពសុខភាពរបស់ជនត្រូវចោទ។ ម្យ៉ាងទៀត បញ្ហាខ្លះដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងថ្មីនេះ មិនដែលត្រូវបានលើកឡើងពីមុនមកទាល់តែសោះ៖ ដូច្នេះ លក្ខខណ្ឌកំណត់នៅក្នុងវិធាន ៦៣(៣) រហូតមកទល់ពេលនេះ មិនដែលត្រូវបានលើកមកធ្វើជាកម្មវត្ថុនៃពាក្យបណ្តឹងសុំដោះលែងឲ្យនៅក្រៅឃុំ ដោយឈរលើមូលដ្ឋាននៃវិធាន ៦៤(២) ពីសំណាក់ជនត្រូវចោទទាល់តែសោះ។

៤. ដោយពិនិត្យលើបញ្ហាទាំងអស់នេះ ការពុំមានការប្រែប្រួលនៃកាលៈទេសៈ មិនអាចត្រូវបានលើកឡើងប្រឆាំងនឹងជនត្រូវចោទទេ ហើយពាក្យបណ្តឹងសុំដោះលែងឲ្យនៅក្រៅឃុំ គឺអាចទទួលយកបាន ។

## II- លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នកំណត់ដោយវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង

### ក) វិធាន ៦៣(៣.ក) នៃវិធានផ្ទៃក្នុង

៥. សហមេធាវីរបស់ជនត្រូវចោទបានលើកឡើងថា អត្ថិភាពជាប្រចាំនៃហេតុផលសមស្រប ដែលអាចនាំឲ្យជឿជាក់បាន គឺជា "លក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ នៃនិយ័តភាព នៃការដាក់ឲ្យនៅក្នុងការឃុំខ្លួន" ហើយវាជាការចាំបាច់ តម្រូវរកឲ្យឃើញ "ដោយច្បាស់លាស់ និងដោយជាក់លាក់នូវធាតុផ្សំ" ដែលសេចក្តីសំរេចយកមកធ្វើជាមូលដ្ឋាននោះ។

៦. សហព្រះរាជអាជ្ញា យល់ឃើញថាពាក្យបណ្តឹងសុំដោះលែងឲ្យនៅក្រៅឃុំ មិនប៉ះពាល់ធ្ងន់ធ្ងរដល់អត្ថិភាពនៃហេតុផលសមស្រប ដែលអាចនាំឲ្យជឿជាក់បានថាជននោះបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបន្ថែមនោះទេ។ សហព្រះរាជអាជ្ញាយោងទៅដល់ទឡ្ហីករណ៍ ដែលបានលើកឡើងនៅក្នុងចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[1] និងបានបន្ថែមថា ការស៊ើបអង្កេតដឹកនាំដោយសហចៅក្រមស៊ើបអង្កេត ស៊ីសង្វាក់គ្នាទៅនឹងចំណុចទាំងឡាយដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

៧. ដើម្បីកំណត់ថា "តើមានហេតុផលសមស្រប ដែលអាចនាំឲ្យជឿបានថា ជននោះបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបន្ថែមនោះដែរឬទេ" វាមានការចាំបាច់ត្រូវកំណត់ថា "តើមានអង្គហេតុ ឬព័ត៌មាន ដែលអាចធ្វើឲ្យអ្នកសង្កេតការណ៍សត្យានុម័តណាម្នាក់ជឿថា មនុស្សដែលពាក់ព័ន្ធបានប្រព្រឹត្តបទល្មើសនោះដែរ ឬអត់[2]"។ លក្ខខណ្ឌនេះត្រូវតែមានជានិច្ច ក្នុងពេលដំណើរការ និងការចំរើនទៅមុខនៃកិច្ចស៊ើបសួរ។ ត្រូវមានការទទួលស្គាល់ផងដែរថា ពាក្យថា "បានប្រព្រឹត្ត" ត្រូវយោងទៅលើទំរង់នៃការចូលរួមដែលមានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់ស្តីពី អ.ត.វ.ក[3]។

---

[1] C26/I/9 ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់ ខៀវ សំផន ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០០៨, ថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ២០០៨, ០០១៦០៧៦៧-០០១៦០៧៨៥ (ANG), §§24-26 et §§33-52។

[2] C11/54, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា, ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨,00154341-00154360, §46 ; C20/I/27, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបន្តោះអាសន្ន របស់ អៀង ធិរិទ្ធ, ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០០៨ , 00201633-00201649(ANG), §21 ; C22/I/73, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបន្តោះអាសន្ន របស់ អៀង សារី, ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០៨ , 002328-30-00232736(ANG), §71.

[3] C11/54, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបន្តោះអាសន្ន របស់ នួន ជា, ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨,00154341-00154360, §47 ; C20/I/27, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបន្តោះអាសន្ន របស់ អៀង ធិរិទ្ធ, ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០០៨ , 00201633-00201649(ANG), §24 ;

៨. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានសំរេចថា ដោយផ្អែកលើកត្តាទាំងឡាយដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ វាមានហេតុផលសមស្របដែលនាំឱ្យជឿបានថា ខៀវ សំផន បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[4]។ លើសពីនេះទៅទៀត ទោះបីជាការស៊ើបអង្កេតកំពុងតែដំណើរការ ហើយថាក្នុងដំណាក់កាលនេះមិនមែនជាដំណាក់កាលនៃការកំណត់ថាតើបន្ទុកចោទប្រកាន់គ្រប់គ្រាន់ក៏ដោយ ក៏ការស៊ើបអង្កេតដែលបានធ្វើរហូតមកដល់ថ្ងៃនេះ បានបង្ហាញឲ្យឃើញពីកត្តាមួយចំនួន ដែលស៊ីសង្វាក់គ្នាទៅនឹងការវិភាគនេះដែរ។

៩. ជាក់ស្តែង ទោះបីជាស្ថិតក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះក៏ដោយ ក៏មានហេតុផលសមស្របដែលនាំឲ្យជឿបានថា ខៀវ សំផន ក្នុងឋានៈរបស់គេជាប្រមុខរដ្ឋ (ប្រធានគណៈប្រធានរដ្ឋ) ជាអ្នកដឹកនាំមន្ទីរនយោបាយមជ្ឈឹម (មន្ទីរ ៨៧០) និងជាសមាជិកពេញសិទ្ធិ នៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនិសកម្ពុជា (បកក) បានដឹង បានសម្រួល និងបានជម្រុញឲ្យមានឧក្រិដ្ឋកម្មដែលគាត់ត្រូវបានដាក់ឲ្យនៅក្រោមការពិនិត្យ ជាពិសេស៖

- ផ្ទុយទៅនឹងអ្វីដែលគាត់បានអះអាង[5] គឺការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ ១៩៧៥[6]
- ការដាក់នូវលក្ខខណ្ឌនៃធ្វើការងារដោយបង្ខំ និងជីវភាពរស់នៅលំបាកទៅលើប្រជាជនកម្ពុជា ការសម្លាប់ និងការធ្វើទុក្ខបុកម្នេញខាងសាសនា ដោយបានធ្វើទស្សនកិច្ចទៅកាន់ការដ្ឋានមួយចំនួននៅទូទាំងប្រទេស[7] និងតាមរយៈព័ត៌មានដែលគាត់ទទួលបាន[8]

---

C22/I/73, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់ អៀង សារី, ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០៨ , 002328-30-00232736(ANG), §71.

[4] C26, ដីកាឃុំខ្លួនបណ្តោះអាសន្នឈ្មោះ ខៀវ សំផន ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧, ០០១៥២៩៩១-០០១៥២៩៩៥ ។

[5] {លុប}

[6] {លុប}

[7] {លុប}

[8] {លុប}

- ការផ្សព្វផ្សាយមនោគមវិជ្ជា និងមាគ៌ានយោបាយរបស់ បកក ដោយការថ្លែងសុន្ទរកថា[9] និងដោយការអប់រំនយោបាយដែលរូបគេបានផ្តល់ ឬដឹកនាំធ្វើ[10] ,
- ការគាក់តែងមាគ៌ានយោបាយរបស់ ប.ក.ក. ការផ្សព្វផ្សាយនយោបាយនេះ និងការដាក់ឲ្យអនុវត្តនៅទូទាំងប្រទេស[11] ក្នុងឋានៈរបស់ខ្លួនជាសមាជិកគណៈកម្មាធិការមជ្ឈឹម ជាអ្នកដឹកនាំមន្ទីរ ៨៧០ ជាប្រធានរដ្ឋ និងដោយបានចូលរួមការប្រជុំនានា[12] ជាពិសេសការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍[13] មួយចំនួន ។ ការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ ក្នុងជួរ បកក[14] ក៏ដូចជាក្នុងមន្ទីរ ៨៧០[15] ដែរ។

១០. សហចៅក្រមស៊ើបអង្កេតគួសបញ្ជាក់ជាថ្មីម្តងទៀតថា មានហេតុផលសមស្របដែលនាំឲ្យជឿបានថា អង្គហេតុទាំងអស់នេះត្រូវបានប្រព្រឹត្តឡើងក្នុងក្របខ័ណ្ឌនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងការវាយកំទេចជាទូទៅ និងជាខ្សែសង្វាក់ ប្រឆាំងទៅនឹងជនស៊ីវិល[16] ។

---

[9] {លុប}

[10] {លុប}

[11] {លុប}

[12] {លុប}

[13] {លុប}

[14] {លុប}

[15] {លុប}

[16] C26, ដីកាឃុំខ្លួនបណ្តោះអាសន្នឈ្មោះ ខៀវ សំផន ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧, ០០១៥២៩៩១-០០១៥២៩៩៥ ។ អង្គបុរេជំនុំជម្រះ បានផ្តល់ការបញ្ជាក់ទៅលើបញ្ហានេះ ដោយឲ្យមានអត្ថន័យបរិបទដូចគ្នាក្នុងសំណុំរឿង ០០២/១៤-០៨-២០០៦ សេចក្តីសំរេចដូចគ្នារបស់សហចៅក្រមស៊ើបអង្កេត ចំពោះជនត្រូវចោទដទៃទៀត ក្នុងក្របខ័ណ្ឌនៃសំណុំរឿងជាមួយគ្នា, C11/54, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបន្តោះអាសន្ន របស់ នួន ជា, ថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨,00154341-00154360, §48 ; C20/I/27, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបន្តោះអាសន្ន របស់ អៀង ធិរិទ្ធ, ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០០៨ , 00201633-00201649(ANG), §24 ; C22/I/73, អង្គបុរេជំនុំជម្រះ, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាឃុំខ្លួនបន្តោះអាសន្ន របស់ អៀង សារី, ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០៨ , 002328-30-00232736(ANG), §74.

១១. អាស្រ័យហេតុនេះ មានហេតុផលសមស្របដែលនាំឲ្យជឿបានថា ជនត្រូវចោទបានជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលខ្លួនត្រូវបានដាក់ឲ្យឋិតក្រោមការពិនិត្យ ពោលគឺ ឃាតកម្ម ការសម្លាប់ផុតពូជ ការឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត ដែលជាសមាសភាគនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមនុស្សឃាតដោយចេតនា អំពើដែលបណ្តាលឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬដែលប៉ះពាល់ធ្ងន់ធ្ងរចំពោះបូរណភាពរាងកាយ ឬសុខភាព អំពើដែលលប់បំបាត់ដោយចេតនានូវការទទួលបានការវិនិច្ឆ័យសេចក្តីដោយសមធម៌របស់អ្នកទោសសង្គ្រាម ឬជនស៊ីវិល ការបណ្តេញចេញ ឬការធ្វើការផ្លាស់ប្តូរទីកន្លែងរស់នៅដោយខុសច្បាប់នៃជនស៊ីវិល គឺជាការបំពារបំពានធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ឬដោយបានផ្តល់ជំនួយ និងការជ្រោមជ្រែងដល់ពួកអ្នកប្រព្រឹត្តអំពើទាំងនោះ៕

## ខ) លក្ខខណ្ឌនៃការឃុំខ្លួនកំណត់ដោយវិធាន ៦៣(៣.ខ)

១២. នៅក្នុងសំណើសុំឲ្យមានការដោះលែងឲ្យមានសេរីភាពជាបន្ទាន់របស់ខ្លួន សហមេធាវីរបស់ជនត្រូវចោទបានលើកឡើងថា លក្ខខណ្ឌចាំបាច់នានាជាសំអាងនៃការសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ដែលកំណត់នៅក្នុងវិធាន ៦៣(៣.ខ) មិនត្រូវបានបំពេញនោះទេ។ ទឡ្ហីករណ៍របស់ពួកគេអាចត្រូវបានសង្ខេបមកដូចខាងក្រោម៖

- ចំពោះលក្ខខណ្ឌទីមួយ និងទីពីរ ដែលទាក់ទងទៅនឹងការរារាំង ការគាបសង្កត់លើជនរងគ្រោះ និងសាក្សី ការថែរក្សាភស្តុតាង ឬការការពារមិនឲ្យបំផ្លាញភស្តុតាង៖ "មិនមានអ្វីបង្ហាញថា លោក ខៀវ សំផន បានគំរាមកំហែង ឬប៉ុនប៉ងគំរាមកំហែងលើសាក្សីនោះទេ"។ "ហានិភ័យនៃការជ្រៀតជ្រែក" នៅតែមានលក្ខណៈជា "ទ្រឹស្តីសុទ្ធសាធ ឬមិនអាចកើតមានឡើងតែម្តង" ព្រោះថា ទោះបីជាជនត្រូវចោទមានលទ្ធភាពចូលមើលសំណុំរឿងបានក៏ដោយ ក៏ជនត្រូវចោទនៅតែមិនអាចដឹងអំពីអត្តសញ្ញាណរបស់ជនដែលនឹងតម្រូវឲ្យផ្តល់សក្ខីកម្មនោះដែរ។

- ចំពោះលក្ខខណ្ឌទីបី ដែលទាក់ទងទៅនឹងការធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី សហមេធាវីបានទទូចថា "លោក ខៀវ សំផន មិនមានលទ្ធភាពណាមួយក្នុងការរត់

គេចខ្លួននោះទេ" ហើយបន្តថា "គាត់បានប្រគល់ខ្លួនដោយស្ម័គ្រចិត្ត"។ លើសពីនេះទៀត អាយុរបស់គាត់ និងស្ថានភាពសុខភាពរបស់គាត់ "រឹតតែធ្វើឲ្យការប៉ុនប៉ងរត់គេចខ្លួនរបស់គាត់ ជារឿងមួយដែលមិនអាចធ្វើទៅបាន" ហើយជាចុងក្រោយ "គាត់មិនមានលិខិតឆ្លងដែនទេ"។

- ចំពោះលក្ខណ្ឌទីបួន ដែលទាក់ទងទៅនឹងការការពារសន្តិសុខឲ្យជនត្រូវចោទ ក្រុមមេធាវីការពារក្ដីអះអាងថា "លោក ខៀវ សំផន បានរស់នៅដោយស្ងប់សុខអស់រយៈពេល ៣០ ឆ្នាំមកហើយ ដោយមិនមានហានិភ័យធ្ងន់ធ្ងរណាមួយចំពោះសន្តិសុខរបស់គាត់ទេ" ហើយចំពោះឧប្បត្តិហេតុនៅក្នុងឆ្នាំ ១៩៩១ ដែលកាលនោះលោក ខៀវ សំផន ត្រូវបានហ្វូងមហាជនវាយប្រហារ នឹងមិនអាច "កើតមានឡើងម្ដងទៀតទេ" ហើយ "ក៏មិនអាចយកធ្វើជាមូលដ្ឋានដើម្បីបញ្ជាក់អំពីហានិភ័យចំពោះសុវត្ថិភាពរបស់គាត់នៅពេលសព្វថ្ងៃនេះដែរ"។

- ជាចុងក្រោយ ចំពោះចំណុចដែលទាក់ទងទៅនឹងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ សហមេធាវីរបស់ជនត្រូវចោទបានពន្យល់ថា "ជនជាប់ឃុំមិនអាចត្រូវបានដាក់ទណ្ឌកម្មចំពោះអំពើហឹង្សា -ណាមួយ- ដែលអ្នកដទៃអាចប្រព្រឹត្តមកលើរូបគាត់នោះទេ" និងបានបន្តថា "វាគឺជាសមត្ថកិច្ចរបស់អាជ្ញាធរមូលដ្ឋាន មិនមែនរបស់លោក ខៀវ សំផន ទេ ក្នុងការរក្សា និងធានាសណ្ដាប់ធ្នាប់សាធារណៈ"។

១៣. នៅក្នុងចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ សហព្រះរាជអាជ្ញាបានបង្ហាញនូវទស្សនទានរបស់ខ្លួនចំពោះទឡ្ហីករណ៍ខាងលើនេះ។ ជំហររបស់សហព្រះរាជអាជ្ញាអាចត្រូវបានសង្ខេបដូចខាងក្រោម៖

- ចំពោះបញ្ហាដែលទាក់ទងទៅនឹងការគាបសង្កត់លើជនរងគ្រោះ និងសាក្សី និងការថែរក្សាភស្តុតាង សហព្រះរាជអាជ្ញាយល់ឃើញថា ជនត្រូវចោទមានលទ្ធភាពចូលមើលសំណុំរឿងទាំងមូលបាន ដូច្នេះគាត់ពិតជាដឹងអំពីអត្តសញ្ញាណរបស់ជនដែលអាចក្លាយជាសាក្សី។ មុខតំណែងរបស់ជនត្រូវចោទ ទាំងក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញថាគាត់គឺជាមនុស្សម្នាក់ដែលមានអំណាច និងមានឥទ្ធិពលនៅក្នុងប្រទេសកម្ពុជា។ សហព្រះរាជអាជ្ញាក៏បានរំលឹកផងដែរ

ថា លោក ខៀវ សំផន ធ្លាប់បានគំរាមកំហែងជាសាធារណៈថា លោកនឹងធ្វើការសងសឹក ប្រសិនបើមាននីតិវិធីតុលាការប្រឆាំងនឹងរូបគាត់។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា គ្មានវិធានការការពារណាមួយត្រូវបានដាក់ចេញ សម្រាប់ការពារសាក្សី និងជនរងគ្រោះនោះឡើយ។

- សហព្រះរាជអាជ្ញាបានលើកឡើងថា ការដាក់ឲ្យនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន វាចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដែលជនត្រូវចោទត្រូវបានដាក់ឲ្យនៅក្រោមការពិនិត្យ គឺជាកត្តាមួយដែលត្រូវពិចារណា ដើម្បីវាយតម្លៃអំពីហានិភ័យនៃការរត់គេចខ្លួន។ ហានិភ័យនៃការរត់គេចខ្លួននេះ គឺវាស្ដែងឡើងយ៉ាងពិតប្រាកដ បើគិតទៅដល់ធនធានហិរញ្ញវត្ថុរបស់ជនត្រូវចោទ ស្ថានភាពភូមិសាស្ត្រជិតគ្នារវាងកន្លែងស្នាក់នៅរបស់ជនត្រូវចោទ និងព្រំដែននៃប្រទេសថៃ និងហេតុដែលថាជនត្រូវចោទមានលិខិតឆ្លងដែន។

- សហព្រះរាជអាជ្ញាយល់ឃើញថា ហានិភ័យចំពោះសន្តិសុខរបស់លោក ខៀវ សំផន អាចនឹងកើតមានប្រសិនបើគាត់ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។ សន្តិសុខរបស់ជនត្រូវចោទអាចនឹងត្រូវបានគំរាមកំហែង ក្នុងពេលដែលនីតិវិធីតុលាការកំពុងដំណើរការ។ ព្រឹត្តិការណ៍ឆ្នាំ ១៩៩១ បានបង្ហាញថា ជនត្រូវចោទធ្លាប់ត្រូវបានគេវាយប្រហាររូបរាងកាយរួចមកហើយ។ ពេលវេលាដែលកន្លងផុតទៅមិនបានកាត់បន្ថយហានិភ័យនេះទេ ផ្ទុយទៅវិញវាកាន់តែធ្វើឲ្យខ្លាំងឡើងៗ។

- ជាចុងក្រោយ ទាក់ទងទៅនឹងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ សហព្រះរាជអាជ្ញាបានលើកឡើងថា ការដោះលែងជនត្រូវចោទឲ្យមានសេរីភាព អាចនឹងបង្កឲ្យមានការបង្ហាញអំពីការមិនសុខចិត្ត ជាហេតុដែលអាចនាំឈានទៅដល់ការប្រើប្រាស់អំពើហិង្សា។

១៤. បន្ទាប់ពីបានបង្ហាញអំពីសេចក្ដីសង្ខេបនៃទឡ្ហីករណ៍របស់ភាគីទាំងឡាយរួចមក សហចៅក្រមស៊ើបអង្កេតបានរំលឹកថា ការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើទៅបាន ប្រសិនបើ

លក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងប្រាំ ដែលមានចែងក្នុងមាត្រា ៦៣(៣) ត្រូវបានបំពេញ[17] ដូច្នេះ សហចៅក្រមស៊ើបអង្កេតមិនចាំបាច់ត្រូវពិនិត្យលើលក្ខណៈវិនិច្ឆ័យនិមួយៗទេ ប្រសិនបើយល់ថា ភាពចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្នត្រូវបានបញ្ជាក់រួចមកហើយ តាមរយៈលក្ខខណ្ឌមួយ ឬច្រើននៃវិធាន ៦៣(៣)។

១៥. ដូចគ្នានឹងសំអាងហេតុ ដែលមានក្នុងសេចក្តីសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃ ទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ទាក់ទងនឹងលក្ខខណ្ឌទីមួយ និងទីពីរ នៃវិធាន ៦៣(៣) សហចៅក្រមស៊ើបអង្កេតបានរំលឹកថា វាមានសារៈសំខាន់ណាស់ចំពោះដំណើរការនៃកិច្ចស៊ើបសួរ ក្នុងការដែលត្រូវធានាបង្ការរាល់ការគាបសង្កត់នានាលើជនរងគ្រោះ និងសាក្សី និងត្រូវថែរក្សាភស្តុតាង។ ពេលវេលាដែលកន្លងផុតទៅ រាប់ចាប់តាំងពីការសម្រេចដាក់ឲ្យជាប់ឃុំបណ្តោះអាសន្ន មិនបានធ្វើឲ្យបាត់ ហានិភ័យទាំងអស់នេះទេ ផ្ទុយទៅវិញវារឹតតែធ្វើឲ្យខ្លាំងឡើងៗ។

១៦. ជនត្រូវចោទមានលទ្ធភាពចូលមើលឯកសារទាំងអស់ ដែលមាននៅក្នុងសំណុំរឿង រួមទាំង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ពិតមែនហើយ មុននឹងមានការចាប់ផ្តើមនីតិវិធីតុលាការ ជនសង្ស័យអាចនឹងលំបាកក្នុងការកំណត់អត្តសញ្ញាណ និងប្រើឥទ្ធិពលលើជនដែលអាចក្លាយជាសាក្សី ដែលមានចំនួនដ៏ច្រើន ប៉ុន្តែវានឹងមិនដូច្នេះទៀតទេ ប្រសិនបើជនត្រូវចោទបានដឹងអំពីអត្តសញ្ញាណរបស់សាក្សីដាក់បន្ទុក និងរបស់ជនរងគ្រោះដែលនៅក្នុងនីតិវិធី។ វាជាក់ច្បាស់ហើយដែលថា ជនត្រូវចោទបានដឹងអំពីសក្ខីកម្មសំខាន់ៗមួយចំនួន ដែលអាចបញ្ជាក់អំពីតួនាទីរបស់គាត់ ជាពិសេសទាក់ទង ទៅនឹងមន្ទីរ ៨៧០[18] និងការជម្លៀសចេញពីក្រុងភ្នំពេញ[19]។ វាមានហានិភ័យមួយដែលជាក់ច្បាស់ គឺថាសាក្សីទាំងនេះនឹងមិនធ្វើការសហការណ៍ឲ្យបានស៊ីជម្រៅទៅក្នុងដំណើរការនៃនីតិវិធីទេ ប្រសិនបើ ខៀវ សំផន ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។ លើសពីនេះទៀត សាក្សីខ្លះៗទៀតក្នុងចំណោមសាក្សីទាំងនេះអាចនឹងត្រូវ

---

[17] សូមមើលជាឧទាហរណ៍ C11/54 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នួន ជា ២០ មិនា ២០០៨ 00154341-00154360 កថាខណ្ឌ ៨៣។

[18] {លុប}

[19] {លុប}

បានស្តាប់ចម្លើយឡើងវិញ ហើយពួកគេក៏បានបង្ហាញផងដែរអំពីតំរុយផ្សេងទៀត និងឈ្មោះរបស់ជនដែលអាចជាសាក្សីផ្សេងៗទៀត ដែលមិនទាន់បានស្តាប់ចម្លើយនៅឡើយ។ វាមានហេតុផលដែលអាចនាំឲ្យជឿជាក់បានថា សាក្សីអាចនឹងទទួលរងការគាបសង្កត់ ព្រោះទីមួយ អាចបណ្តាលមកពីហេតុដែលថា ពួកគេធ្លាប់ជាអ្នកនៅក្រោមបង្គាប់របស់ជនត្រូវចោទ និងទីពីរមាន លក្ខណៈទូទៅជាងដោយសារមុខតំណែងរបស់ជនត្រូវចោទ។ ហានិភ័យនេះវាពិតជាក់ស្តែង ហើយដែលត្រូវបានបញ្ជាក់គាំទ្រដោយសម្តីជាសាធារណៈរបស់ជនត្រូវចោទ ទាក់ទងទៅនឹងការគំរាមសងសឹក ប្រសិនបើនីតិវិធីតុលាការត្រូវបានដំណើរការប្រឆាំងនឹងរូបគាត់[20]។ ដូច្នេះវាពិតជាមានហានិភ័យនៃការគាបសង្កត់ពិតប្រាកដមែន ដែលតម្រូវឲ្យត្រូវបង្ការហានិភ័យទាំងនោះ ដើម្បីធានាដំណើរការនៃកិច្ចស៊ើបសួរ។

១៧. ដូចគ្នាទៅនឹងការបកស្រាយរបស់អង្គបុរេជំនុំជម្រះដែរ សហចៅក្រមស៊ើបអង្កេតចាត់ទុកថា លក្ខខណ្ឌនៃការរក្សាសណ្តាប់ធ្នាប់សាធារណៈត្រូវបានបំពេញ ប្រសិនបើមានអង្គហេតុ ដែលអាចបញ្ជាក់ថា ការដោះលែងឲ្យមានសេរីភាពអាចនឹងប៉ះពាល់យ៉ាងពិតប្រាកដដល់សណ្តាប់ធ្នាប់សាធារណៈ។ ជាងនេះទៀត ការឃុំខ្លួននៅតែស្របច្បាប់ ប្រសិនបើសណ្តាប់ធ្នាប់សាធារណៈនៅតែត្រូវបានគំរាមកំហែង[21]។ ចំពោះពាក្យ “អង្គហេតុដែលអាចបញ្ជាក់” ទាក់ទងជាសំខាន់ចំពោះការប្រព្រឹត្តនៅក្នុងបរិបទនៃឧក្រិដ្ឋកម្ម ដែលនៅក្នុងដែនយុត្តាធិការរបស់ អ.វ.ត.ក[22]។

១៨. ជាក់ស្តែង ទោះបីជាវាកន្លងផុតទៅជិត ៣០ ឆ្នាំហើយក៏ដោយ ក៏ឥទ្ធិពលនៃរបបខ្មែរក្រហមមកលើសង្គមកម្ពុជា នៅតែមិនទាន់ផុតរលត់នៅឡើយទេ ហើយមួយផ្នែកនៃសង្គមកម្ពុជាទទួល

---

[20] {លុប}

[21] C11/54 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា ២០ មីនា ២០០៨ ០០១៥៤៣៤១-០០១៥៤៣៦០ កថាខណ្ឌ ៧៦។ C20/I/27 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង ធីរីទ្ធ ៩ កក្កដា ២០០៨ ០០២០១៦៣៣-០០២០១៦៤៩ (អង់គ្លេស) កថាខណ្ឌ ៦៤។

[22] C22/I/73 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី ១៧ តុលា ២០០៨ ០០២៣២៨-៣០-០០២៣២៧៣៦ (អង់គ្លេស) កថាខណ្ឌ ១១២។

រងនូវវិបត្តិបាក់ស្បាតផ្នែកស្មារតី[23]។ ចំណាប់អារម្មណ៍របស់ប្រជាជន និងសារព័ត៌មានកម្ពុជាចំពោះអង្គជំនុំជម្រះវិសាមញ្ញ និងនីតិវិធីដែលកំពុងដំណើរការ បានបង្ហាញថាវាគឺជាប្រធានបទដែលជាទីចាប់អារម្មណ៍ចំពោះសង្គមកម្ពុជា។

១៩. សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដែលជនត្រូវចោទត្រូវបានដាក់ឲ្យឋិតក្រោមការពិនិត្យ មិនមែនជាឧបសគ្គដាច់ខាតដល់ការដោះលែងឲ្យមានសេរីភាពនោះទេ។ ផ្ទុយទៅវិញ វាជាកត្តាមួយដែលត្រូវពិចារណា ក្នុងការត្រួតពិនិត្យលក្ខណៈវិនិច្ឆ័យនៃការសម្រេចចិត្តបន្តការឃុំខ្លួនបណ្តោះអាសន្ន និងអំពីចរិតសមស្របនៃវិធានការដែលដាក់ចុះ។ ជាក់ស្តែង បើយោងទៅដល់ភាពធ្ងន់ធ្ងរនៃអង្គហេតុ ដែលជនត្រូវចោទត្រូវបានដាក់ឲ្យឋិតក្រោមការពិនិត្យ វាមិនជាការហួសហេតុពេកទេដែលថា សេចក្តីសម្រេចដោះលែងឲ្យមានសេរីភាព ដែលធ្វើឡើងក្នុងបរិបទនៃសង្គមកម្ពុជាសព្វថ្ងៃដែលផុយស្រួយ អាចនឹងបណ្តាលឲ្យមានការមិនសុខចិត្ត ដែលអាចឈានទៅដល់ការប្រើប្រាស់អំពើហឹង្សា។

២០. ចំពោះបញ្ហាដែលទាក់ទងទៅនឹងសន្តិសុខរបស់ជនត្រូវចោទ ទឡ្ហីករណ៍ដែលថា ខៀវ សំផន បានរស់នៅស្ងប់សុខអស់រយៈពេល ៣០ឆ្នាំ ដោយពុំមានហានិភ័យជាសំខាន់ណាមួយដល់សន្តិសុខរបស់គាត់ នឹងមិនត្រូវបានចាត់ទុកថាត្រឹមត្រូវទេ ព្រោះវាឋិតនៅក្នុងស្ថានភាពខុសគ្នាបន្ទាប់ពីមានការដាក់ឲ្យដំណើរការជាផ្លូវការនៃនីតិវិធីតុលាការ ហើយហានិភ័យនៃការសងសឹកជាលក្ខណៈផ្ទាល់ខ្លួន ពីសំណាក់ជនរងគ្រោះមួយ ឬច្រើន មិនអាចត្រូវបានលុបបំបាត់ទាំងស្រុងនោះទេ។ ទោះបីជាពេលវេលាកន្លងផុតទៅមែន តែហានិភ័យនេះមិនបានថយចុះនោះទេ ព្រោះថាគ្រោះថ្នាក់ចំពោះសន្តិសុខ របស់ជនត្រូវចោទកាន់តែកើនឡើង ជាមួយនិងការនិយាយអំពីនីតិវិធីតុលាការនៅតាមប្រព័ន្ធផ្សព្វផ្សាយ។

---

[23] សូមមើលជាឧទាហរណ៍ C22/I/73 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី ១៧ តុលា ២០០៨ ០០២៣២៨-៣០-០០២៣២៧៣៦ (អង់គ្លេស) កថាខណ្ឌ ១១៣។

២១. នៅក្នុងដីកាសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតបានអះអាង ហើយបានរំលឹកជាដដែលថា ភាពធ្ងន់ធ្ងរនៃអង្គហេតុ ដែលជនត្រូវចោទត្រូវបានដាក់ឲ្យឋិតនៅក្រោម ការពិនិត្យ និងការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ ប្រសិនបើជនត្រូវចោទត្រូវបានដោះ លែង អាចនឹងធ្វើឲ្យសន្តិសុខរបស់ជនត្រូវចោទឋិតនៅក្នុងគ្រោះថ្នាក់។ ជាងនេះទៅទៀត ប្រសិនបើ ព្រឹត្តិការណ៍ក្នុងឆ្នាំ ១៩៩១ ដែលកាលនោះ ខៀវ សំផន ត្រូវបានដេញវាយឲ្យបែកក្បាលដោយហ្វូង មហាជនដែលពោរពេញដោយកំហឹង[24] មិនអាចបញ្ជាក់អំពីហានិភ័យបច្ចុប្បន្នរបស់ជនត្រូវចោទបាន ទេ តែវាក៏អាចជាធាតុមួយដែលគាំទ្រដល់សេចក្តីសន្និដ្ឋានដូចខាងលើ ហើយគ្មានអ្វីដែលអាចធានា អះអាងបានថា ព្រឹត្តិការណ៍បែបនោះនឹងមិនអាចកើតមានឡើងម្តងទៀតនោះទេ។

២២. ជាចុងបញ្ចប់ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វានៅតែមានហានិភ័យយ៉ាងពិត ប្រាកដ ចំពោះរឿងដែលថា ជនត្រូវចោទធ្វើការគាបសង្កត់លើជនរងគ្រោះ និងសាក្សី។ ហើយចាត់ ទុកថា ការទុកឲ្យជនត្រូវចោទនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន វាជាការចាំបាច់សម្រាប់ការថែរក្សា ភស្តុតាង និងជៀសវាងការបំផ្លាញភស្តុតាង ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ និងរក្សាសណ្តាប់ ធ្នាប់សាធារណៈ។

## III-អវត្តមាននៃដំណោះស្រាយផ្សេងពីនេះ

២៣. ទោះបីជានៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន សហមេធាវីបានស្នើសុំត្រឹមតែការដោះលែង ជនត្រូវចោទឲ្យមានសេរីភាព តែនៅក្នុងទឡ្ហីករណ៍ សហមេធាវីក៏បានស្នើសុំផងដែរនូវវិធានការផ្សេង ទៀត ដូចជាការឃុំខ្លួននៅក្នុងគេហដ្ឋាន។ សហមេធាវីបានលើកឡើងថា ការដកហូតសេរីភាព "ត្រូវតែមានលក្ខណៈចាំបាច់" និង "សមាមាត្រ" ទៅនឹងកាលៈទេសៈ និងជា "វិធានការសមស្របតែ មួយគត់ ឆ្លើយតបទៅនឹងមូលហេតុ" បើមិនដូច្នេះទេ ត្រូវអនុម័តយក "វិធានការណា ដែលប៉ះពាល់តិច ដល់សិទ្ធិរបស់បុគ្គល"។

---

[24] {លុប}

២៤. ជាចម្លើយតបទៅនឹងទឡ្ហីករណ៍នេះ សហព្រះរាជអាជ្ញាបានអះអាងថា មិនមានវិធានការណាផ្សេងទៀត ដែលមានលក្ខណៈតឹងរឹងគ្រប់គ្រាន់ សម្រាប់ឆ្លើយតបទៅនឹងភាពចាំបាច់នៃការការពារសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ការរក្សាសណ្តាប់ធ្នាប់សាធារណៈ និងការរារាំងមិនឲ្យជនត្រូវចោទធ្វើការគាបសង្កត់លើជនរងគ្រោះ និងសាក្សី ឬបំផ្លាញភស្តុតាងនោះទេ។

២៥. ទាក់ទិននឹងបញ្ហានេះ សហចៅក្រមស៊ើបអង្កេតឯកភាពជាមួយនឹងជំហររបស់អង្គបុរេជំនុំជម្រះ ដែលបានលើកឡើងជាច្រើនលើកច្រើនសារថា កាលណាលក្ខខណ្ឌភាគច្រើន ឬលក្ខខណ្ឌទាំងអស់ ដែលកំណត់នៅក្នុងមាត្រា ៦៣ (៣.ខ) ត្រូវបានបំពេញរួចហើយ ឬទោះបីជាមានលក្ខខណ្ឌតែមួយប៉ុណ្ណោះ ត្រូវបានបំពេញ ក៏អាចសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្នបានផងដែរ។ នេះគឺជាសញ្ញាមួយចម្បង ដែលបញ្ជាក់ប្រាប់ថា គ្មានវិធានការត្រួតពិនិត្យណាផ្សេងទៀត ដែលមានលក្ខណៈតឹងរឹងចាំបាច់គ្រាប់គ្រាន់ ជាងការដាក់ឲ្យនៅក្នុងឃុំបណ្តោះអាសន្ននោះទេ[25]។ ដូចគ្នានេះ សហចៅក្រមស៊ើបអង្កេតក៏នៅរក្សាជំហររបស់ខ្លួន ដូចដែលមាននៅក្នុងដីកាសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្នៈ ភាពធ្ងន់ធ្ងរនៃអង្គហេតុ ដែលខៀវសំផនត្រូវបានដាក់ឲ្យឋិតនៅក្រោមការពិនិត្យ ធ្វើឲ្យហានិភ័យ ដែលមាត្រា ៦៣(៣.ខ) ព្យាយាមបង្ការ កាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ។ ដូច្នេះមិនមានវិធានការណ៍ត្រួតពិនិត្យតាមផ្លូវតុលាការណាផ្សេងទៀត ដែលអាចធានាប្រសិទ្ធភាពនៃបទប្បញ្ញត្តិខាងលើនេះបានទេ។

## IV-រយៈពេលនៃការឃុំខ្លួនមិនហួសហេតុ

២៦. សហមេធាវីរបស់លោក ខៀវ សំផន អះអាងថា កូនក្តីរបស់ខ្លួនត្រូវបានឃុំខ្លួនអស់រយៈពេលលើសពី ១០ ខែហើយ និងថាទោះបីជាចៅក្រមនឹងចេញសេចក្តីសម្រេចបែបណាក៏ដោយ មិនថាជាដីកាលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ការសម្រេចដូចនេះបាន មិន

[25] សូមមើលសេចក្តីសម្រេចថ្មីៗនេះ៖ C22/I/73 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី ១៧ តុលា ២០០៨ ០០២៣២៨-៣០-០០២៣២៧៣៦ (អង់គ្លេស) កថាខណ្ឌ ១២១។

អាចធ្វើបានភ្លាមទេ គឺត្រូវចំណាយពេលរាប់ខែទៀត ហេតុដូច្នេះ ជនត្រូវចោទ នឹងត្រូវជាប់ឃុំជាបន្តទៀតមុននឹងមាន "សេចក្តីសម្រេចណាមួយត្រូវបានធ្វើឡើង ដែលនេះជាប្រការមិនត្រឹមត្រូវទាល់តែសោះ"។ សហមេធាវី ក៏ចង្អុលបង្ហាញផងដែរថា ជាមួយនឹងពេលវេលាដែលកន្លងផុតទៅ ការយកចិត្តដាក់ចំពោះនីតិវិធី ត្រូវតែជាធាតុមួយដែលត្រូវពិចារណានៅក្នុងការសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

២៧. ពេលវេលាដែលកន្លងផុតទៅ គឺជាធាតុមួយសម្រាប់យកមកធ្វើការពិចារណាដើម្បីសម្រេចពីលក្ខណៈសមស្របនៃការរក្សាការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ។ ពេលវេលានៃការឃុំខ្លួនបណ្តោះអាសន្នដែលកន្លងផុតទៅ មិនត្រូវបានចាត់ទុកថាមិនត្រឹមត្រូវទេ ប្រសិនបើមានភស្តុតាងបង្ហាញថា នីតិវិធីប្រព្រឹត្តទៅប្រកបដោយការយកចិត្តទុកដាក់។ ដើម្បីវាយតម្លៃពីរបៀបនៃការដឹកនាំនៃកិច្ចស៊ើបសួរនេះ និងដោយប្រៀបធៀបទៅនឹងយុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុបសម្រាប់សិទ្ធិមនុស្ស លើបញ្ហារយៈពេលសមស្រប សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាជាការចាំបាច់ដែលត្រូវគិតដល់អង្គហេតុទាំងមូល និងជាពិសេសអំពីភាពស្មុគស្មាញខាងអង្គហេតុ និងអង្គច្បាប់នៃរឿងក្តី ការប្រព្រឹត្តរបស់អាជ្ញាធរតុលាការ និងឥរិយាបថរបស់ភាគី[26]។

២៨. នៅក្នុងរឿងនេះ ជនត្រូវចោទ ត្រូវបានជាប់ឃុំ អស់រយៈពេលប្រមាណជា ១២ ខែ។ រយៈពេលនេះ មិនមានលក្ខណៈហួសហេតុទេ បើគិតពីទំហំធំនៃកិច្ចស៊ើបសួរ ភាពស្មុគស្មាញ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបញ្ជូនមកសហចៅក្រមស៊ើបអង្កេត[27]។

២៩. ចាប់តាំងពីបើកការស៊ើបសួរមក សហចៅក្រមស៊ើបអង្កេត បានដឹកនាំការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋទាំងនេះ។ ហើយ បន្ទាប់ពីដាក់ឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទមក សហចៅក្រមស៊ើបអង្កេត បានប្រមូលភស្តុតាងជាច្រើន ទៅតាមសំណើសុំរបស់ភាគីនានា ឬទៅតាមការផ្តួចផ្តើម

---

[26] CEDH, ដីកា *Frydlender ទល់នឹង France* ចុះថ្ងៃទី ២៧ មិថុនា ២០០០, លេខ 30979/96 §៤៣; CEDH ដីកា *Pelissier និង Sassi ទល់នឹង France* ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ១៩៩៩ , លេខ 25444/94 §៧១; CEDH ដីកា *Vernillo ទល់នឹង France* ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ១៩៩១, លេខ 11889/85 §៣៤។

[27] {លុប}

របស់ខ្លួនផ្ទាល់ និងបានសួរចម្លើយបុគ្គលផ្សេងទៀត តួយ៉ាងអំពីតួនាទីសំខាន់ៗដែល ខៀវ សំផន មាន។ កំណត់ហេតុស្ដាប់ចម្លើយសាក្សីចំនួន ១៤៦ ត្រូវបានដាក់ចូលក្នុងសំណុំរឿង ដែលមានមួយចំនួនបានផ្ដល់ព័ត៌មានជាក់លាក់ អំពីតួនាទីដែលជនត្រូវចោទមាននៅក្នុងរបបនោះ។ លើសពីនេះទៀត ដីកាចាត់ឱ្យស៊ើបសួរជំនួសជាច្រើនកំពុងត្រូវបានអនុវត្ត។ ចុងបញ្ចប់ ជនត្រូវចោទ ក៏ត្រូវបានសួរចម្លើយផងដែរ រហូតដល់ពេលដែលជនត្រូវចោទសម្រេចប្រើសិទ្ធិនៅស្ងៀម។ សិទ្ធិនៅស្ងៀមត្រូវបានទទួលស្គាល់ និងមិនអាចជំទាស់បាន ប៉ុន្តែវាមិនបានចូលរួមចំណែកដល់ការពន្លឿននីតិវិធីទេ។

៣០. អាស្រ័យដូចបានរៀបរាប់ខាងលើនេះ ការកន្លងផុតទៅនៃពេលវេលា នឹងមិនប៉ះពាល់ដល់លក្ខណៈចាំបាច់នៃការរក្សាការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងរឿងនេះទេ។

## V-អាយុ និងស្ថានភាពសុខភាពរបស់ជនត្រូវចោទ មិនមានទំនាក់ទំនងនឹងការរក្សាការឃុំខ្លួនបណ្ដោះអាសន្នទេ

៣១. សហមេធាវីជនត្រូវចោទ លើកឡើងពីអាយុ និងស្ថានភាពសុខភាពរបស់កូនក្ដីខ្លួន ដើម្បីយកមកធ្វើជាទឡ្ហីករណ៍សំរាប់ការស្នើសុំរបស់ខ្លួន។ សហមេធាវីបញ្ជាក់អះអាងថា ការរក្សាការឃុំខ្លួន "អាចបង្កើតនូវការប្រព្រឹត្តដ៏អាក្រក់ ឬយ៉ាងហោចណាស់ អាចធ្វើជាយុត្តិកម្មយ៉ាងពេញលេញលើការដោះលែងគាត់ឱ្យមានសេរីភាព"។

៣២. សហព្រះរាជអាជ្ញា បញ្ជាក់អះអាងថា បញ្ហាអាយុ និងសុខភាពរបស់ជនត្រូវចោទត្រូវបានលើកឡើងដោយមេធាវីការពារក្ដីម្ដងរួចហើយ នៅក្នុងពាក្យសុំដោះលែងឱ្យមានសេរីភាពលើកមុន។ ពាក្យសុំនេះត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែចាប់តាំងចេញដីកានោះមក ស្ថានភាពសុខភាពរបស់ជនត្រូវចោទ មានការលក្ខណៈប្រសើរឡើងយ៉ាងខ្លាំង។

៣៣. ដូចដែលបានកត់សំគាល់នាពេលកន្លងទៅថ្មីៗនេះ[28] ការដោះលែងជនត្រូវចោទឲ្យមានសេរីភាព អាចធ្វើឡើងឈរលើមូលដ្ឋានមាត្រា ៦៤(២) ប្រសិនបើមានការបង្ហាញថា ស្ថានភាពសុខភាពរបស់ជនត្រូវចោទ មានវិសមិតភាពនឹងការរក្សាការឃុំខ្លួនបណ្តោះអាសន្ន។ អាយុច្រើនមិនបង្កើតជាឧបសគ្គដល់ការឃុំខ្លួនទេ[29]។ វិសមិតភាពរវាងការឃុំខ្លួន ជាមួយនឹងអាយុ និងស្ថានភាពសុខភាពរបស់ជនត្រូវចោទ ត្រូវបានវិភាគទៅតាមករណីនីមួយៗ ដោយផ្អែកទៅលើស្ថានភាពទាំងមូលនៃសាច់រឿង[30]។

៣៤. បន្ទាប់ពីគ្រោះថ្នាក់ដាច់សរសៃឈាមក្នុងខួរក្បាលដែលបានរកឃើញនៅក្នុងថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៨ សហមេធាវីជនជាប់ចោទ នៅថ្ងៃទី ១៣ មិថុនា ឆ្នាំ ២០០៨ បានស្នើសុំដល់សហចៅក្រមស៊ើបអង្កេតចេញដីកាដោះលែង ខៀវ សំផន ឲ្យមានសេរីភាព ដោយហេតុផលសុខភាព។ នៅក្នុងដីកាបដិសេធចុះថ្ងៃទី ៤ ខែកក្កដា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើសុំនេះ ដោយហេតុផលថា "វាដូចជាឆាប់ពេកដែលអះអាងថា ស្ថានភាពសុខភាពរបស់ជនត្រូវចោទនៅពេលបច្ចុប្បន្ន មានវិសមិតភាពនឹងការឃុំខ្លួន"។ ស្របគ្នានេះដែរ សហចៅក្រមស៊ើបអង្កេត បានរំលឹកថា ការធ្វើកោសល្យវិច័យផ្នែកប្រសាទសាស្ត្រលើកទី ២ ត្រូវបានបញ្ជាឲ្យធ្វើ និងបានពន្យល់ថា ក្នុងករណីចាំបាច់ ខ្លួននឹងចេញ[31] "សេចក្តីសម្រេចសមស្របទាក់ទិននឹងការឃុំខ្លួន"។

---

[28] C36 III, ដីកាបដិសេធការដោះលែង ខៀវ សំផន ឲ្យមានសេរីភាព ថ្ងៃទី ២៣ មិថុនា ឆ្នាំ ២០០៨, 00197169-00197173។

[29] CEDH, Papon តទល់នឹង France, បណ្តឹងលេខ ៦៤៦៦៦/០១ ថ្ងៃទី ៧ មិថុនា ឆ្នាំ ២០០១ (Papon នៅពេលនោះមានអាយុ ៩០ ឆ្នាំ)។

[30] CEDH, Mouisel តទល់នឹង France, បណ្តឹងលេខ ៦៧២៦៣/០១ ថ្ងៃទី ១៤ វិច្ឆិកា ឆ្នាំ ២០០២ កថា. ៣៧; CEDH, Papon តទល់នឹង France, បណ្តឹងលេខ ៦៤៦៦៦/០១ ថ្ងៃទី ៧ មិថុនា ឆ្នាំ ២០០១; CEDH, Priebke តទល់នឹង Italie, បណ្តឹងលេខ ៤៨៧៩៩/៩៩ ថ្ងៃទី ៥ មេសា ឆ្នាំ ២០០១។

[31] B11, ដីកាចាត់តាំងអ្នកជំនាញខាងប្រសាទសាស្ត្រ ខៀវ សំផន ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៨, 00204332-00204334។

៣៥. កោសល្យវិច័យផ្នែកប្រសាទសាស្ត្រខាងលើ ត្រូវបានធ្វើឡើងដោយសាស្ត្រាចារ្យ Chong-Tin Tan និងវេជ្ជបណ្ឌិត ចាន់ សំលេង នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៨ ហើយរបាយការណ៍ពិនិត្យ ត្រូវបានដាក់ក្នុងសំណុំរឿងលេខ ១ នៅថ្ងៃទី ១ ខែសីហា ឆ្នាំ ២០០៨[32]។ របាយការណ៍ បង្ហាញថា "លោក ខៀវ សំផន បានជាឡើងវិញហើយ" {លុប}។ វេជ្ជបណ្ឌិតបានធ្វើសេចក្តីសន្និដ្ឋានដូច្នេះថា "ស្ថានភាពនៃការឃុំខ្លួនរបស់ជនត្រូវចោទនាពេលបច្ចុប្បន្ន មានសមិតភាពនឹងស្ថានភាពសុខភាព" និងថា ចាប់ពីចុងខែកក្កដា ឆ្នាំ ២០០៨ ទៅ ជនត្រូវចោទ នឹងមាន "សម្បទាខាងរូបរាងកាយ និងចិត្ត ចូលរួមក្នុងនីតិវិធីតុលាការបាន"។

៣៦. នាពេលថ្មីៗនេះ ជនត្រូវចោទ ត្រូវបានពិនិត្យជាថ្មីម្តងទៀតដោយសាស្ត្រាចារ្យ Antoine Lefont និងវេជ្ជបណ្ឌិត សុខ ជួ អ្នកជំនាញខាងបេះដូង ទៅតាមសំណើរបស់សហចៅក្រម ស៊ើបអង្កេត។ របាយការណ៍កោសល្យវិច័យ ដែលបានដាក់ក្នុងសំណុំរឿងនៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨[33] សន្និដ្ឋានថា "មានការវិវត្តន៍ល្អហើយ" {លុប}។

៣៧. {លុប}

---

[32] B11/2, របាយការណ៍របស់អ្នកជំនាញខាងប្រសាទសាស្ត្រ ខៀវ សំផន ចុះថ្ងៃទី ១ ខែសីហា ឆ្នាំ ២០០៨, 00223817-00223822។

[33] B13, ដីកាចាត់តាំងអ្នកជំនាញលើ ខៀវ សំផន ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០០៨, 00226119-00226121។ B13/1, របាយការណ៍របស់អ្នកជំនាញលើ ខៀវ សំផន ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨, ។

៣៨. សហចៅក្រមស៊ើបអង្កេត នឹងបន្តតាមដានពីការវិវត្តន៍នៃសុខភាពរបស់ជនត្រូវចោទ ប៉ុន្តែនៅពេលនេះ បន្ទាប់ពីបានពិនិត្យរាល់ចំណុចទាំងអស់រួមមក ស្ថានភាពសុខភាពរបស់ ខៀវ សំផន មានសមិតភាពនឹងការរក្សាការឃុំខ្លួនបណ្តោះអាសន្ន។

**ហេតុដូច្នេះ**

**បដិសេធ** សំណើសុំដោះលែង ខៀវ សំផន ឲ្យមានសេរីភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**